
ចាំសន្យា?




ក្លិបយុវវ័យដើម្បីអភិវឌ្ឍន៍ ជួបជុំគ្នាស្តាប់ កម្មវិធី យើងអាចធ្វើបាននៅផ្ទះបូរិន
កម្មវិធី យើងអាចធ្វើបាន


សាឯម ភ្លឹកដល់ណាហើយ?
ព្រលឹងអត់នៅក្នុងខ្លួនសោះ?
ពុកម៉ែ ចង់ឱ្យខ្ញុំឈប់រៀន ហើយទៅធ្វើការនៅទីក្រុង ព្រោះរាំងស្ងួតជីវភាពខ្វះខាត... ខ្ញុំអត់ចង់ទៅទេ!
ហ៊ឺ...ម៉ែចង់ឱ្យខ្ញុំឈប់រៀន ហើយទៅស៊ីឈ្នួលគេដែរ... យើងប្រហែលលែងបានជួបគ្នាស្ដាប់វិទ្យុទៀតហើយ...
គ្នាក៏អញ្ចឹងដែរ...
ពួកយើង ស្ដាប់កម្មវិធី សិនទៅ គេនិយាយពីអី...!
វិសាល យើងទាំងអស់គ្នាត្រូវ តាមដានសកម្មភាពតំណាងរាស្ត្រ ថាគាត់បានធ្វើតាមពាក្យសន្យារបស់គាត់ដែរ រឺទេ?
ត្រូវហើយរដ្ឋា! យើងអាច សាកសួរព័ត៌មានពីខាង សាលាឃុំ និងការិយាល័យ តំណាងរាស្ត្រ
នែ...ម៉េចយើងមិនទៅសួរ ខាងឃុំសាកមើល ក្រែងអាច ជួយបាន?
មែនហើយ
ល្អតើ


បូរិន-សុភា-សាឯម ទៅសាលាឃុំ
សាលាឃុំ ប្រសើរ
ជំរាបសួរ មីង ជំរាបសួរតា...
ល្អហើយ លើកដៃថ្វាយព្រះ
ពួកខ្ញុំមកនេះ ចង់សួរពីប្រឡាយទឹក ព្រោះឥឡូវនេះរាំងស្ងួត អត់ទឹកធ្វើស្រែទេ
បើអត់មាន
ស្រាយទេ ម៉ែឱ្យខ្ញុំ
ហើយ...
ត្រូវម៉ាច់ តាកំពុងតែ មកសួររឿងនេះដែរ



ខាងឃុំកំពុងតែគិតដែរ តែអត់មានថវិកាគ្រប់គ្រាន់សំរាប់ជីកប្រឡាយទេ...ឃុំចង់ប្រមូលប្រាក់បដិភាគ តែមើលទៅអ្នកភូមិយើង ដូចជាខ្វះខាតណាស់
ធ្វើម៉េចទៅអញ្ចឹង?
មីង តើខាងតំណាងរាស្ត្រ អាចជួយបានទេ? ពេលឃោសនាបោះឆ្នោត គាត់បានសន្យាច្រើនណាស់
អាទិត្យនេះ ខាងអង្គការសង្គមស៊ីវិល និងរៀបចំវេទិការសាធារណៈ នៅវត្ត យើង... លោកតំណាងរាស្ត្រក៏មកដែរ យើងអាចសួរគាត់ដោយផ្ទាល់...
បើអញ្ចឹងល្អណាស់
ត្រូវម៉ាច់


វេទិការសាធារណៈរៀប ចំនៅវត្ត
វត្តពោធិមានជ័យ


វេទិការសាធារណៈ
រាស្ត្រ និងតំណាងរាស្ត្រ


សូមអញ្ជើញ សួរជា បន្តបន្ទាប់


លឺតែអភិវឌ្ឍន៍តែដូចជាគ្មានឃើញអីផង
មែនហ្នឹង
សួរទៅសុភា!
សួរក៏បានដែរ
ល្អណាស់...
នាងខ្ញុំឈ្មោះសោភា សូមសួរទៅពូតំណាងរាស្ត្រថា តើពេលណាលោកពូជីកប្រឡាយទឹកក្នុងភូមិខ្ញុំ តាមការសន្យាពេលឃោសនាបោះឆ្នោត សូមអរគុណ
ត្រូវម៉ាច់
ខ្ញុំក៏ចង់ដឹងរឿងនេះដែរ
ទាក់ទងនឹកបញ្ហាជីកប្រឡាយទឹកនេះ ខាងខ្ញុំកំពុងតែគិតគូរយ៉ាងយកចិត្ត ទុក-ដាក់ ហើយសង្ឃឹមថាគំរោងនេះនិងបានចេញនាឆាប់ៗ
សង្ឃឹមថាបានដូចមាត់ទៅចុះ
តែប៉ុណ្ណឹងមានសង្ឃឹមវិញហើយ


ត្រូវម៉ាច់ ហើយបូរិន...
បើនៅតែយ៉ាងនេះ ច្បាស់ជាដាច់ពោះស្លាប់មិនខានទេ
ពេលតំណាងរាស្ត្រសន្យា ខ្ញុំខំតែមាន សង្ឃឹម តែចាំបាត់ៗ...
យើងខំសរសេរសំបុត្រទៅរំលឹកគាត់ដល់ការិយាល័យតំណាងរាស្ត្រទៀត តែគាត់ឱ្យយើងចាំដដែល...
ស្អែកប្រជុំក្រុម ប្រឹក-ព្រាឃុំសង្កាត់ ចាំមើលៗ គេដោះស្រាយយ៉ាងម៉េច?
ស្អែកខ្ញុំនិងទៅស្តាប់ដែរ...


នៅបរិវេណសាលាឃុំ
សាលាឃុំ ប្រសើរ
ប៉ាសុភាម៉ោដែរ?
បាទ មកស្តាប់អោយដឹងរឿងនិងគេខ្លះ...
ខាងឃុំមានតែម៉ាស៊ីនបូមទឹក និងទុយោប៉ុន្មានរយម៉ែត្រ ទេ...
តើបងប្អូនគិតយ៉ាងម៉េចដែរ?
- អត់មានទឹក
- ស្រូវស្លក
- ផ្លូវពិបាកច្រើន


សាំង យើងអាចចូលលុយគ្នា
ទិញបាន តែទុយោថ្លៃណាស់
ម្យ៉ាងប្រភពទឹកនៅឆ្ងាយទៀត
រឿងទុយោទឹក ខ្ញុំអាចជួយបាន
ព្រោះខ្ញុំមានច្រើនគួរសមដែរ
ប៉ាសុភាឯងចិត្ត
បានណាស់
ចិត្តបានដូចសុភាហ្នឹង
អញ្ជឹងយើងដោះស្រាយបានហើយ...
អរគុណបងប្អូនដែលចេះសាមគ្គីគ្នា
ដោះស្រាយរឿងនេះ...


សកម្មភាពប្រជាជនតទុយោបូមទឹក




បូរិនបណ្ដុះផ្សិតចំបើង


គ្រួសារសាងមប្រកបរបរបន្ថែម ដើម្បីទប់ទល់ជីវភាព


សន្ទូងចាប់ផ្ដើមលាស់


សាងម
បានអីកាន់ហ្នឹង?
ស្ករផែនធ្វើថ្មីៗ...
ខ្ញុំយកមកចែកគ្នា
តេះលេង
បានធ្វើស្ករនេះហើយ គ្រាន់បានទប់ទល់ជីវភាពក្នុងផ្ទះ
កុំអីយើងគ្មានបានជួបគ្នាទេ...
ខ្ញុំដាំផ្សិតចំបើងដែរហ្នឹង
ដល់កម្មវិធីល្អម
តោះយើងនាំគ្នាស្ដាប់
យើង...យើង...
អាចធ្វើបាន...

## ឈុតទី៩ ៖ នៅវាលស្រែ ពេលថ្ងៃ




មីង... យើតប្រសើរជាងអត់
នេះក៏ចាត់ទុកថា តំណាងរាស្ត្រ មិនប្រងើយ កន្តើយចំពោះយើងដែលជាម្ចាស់ឆ្នោតដែរ
ការសន្យាមួយបានឆ្លើយតបហើយ.. តែនៅ-មានសន្យាជាច្រើនទៀត ដែលយើងត្រូវតាមដានមើលបន្ត
តាមដានម៉េចទៅ?
យើងអាចសាកសួរតាមរយៈសាលាឃុំ ការិយាល័យតំណាងរាស្ត្រ
យើងអាចស្តាប់តាមវិទ្យុ មើលទូរទស្សន៏ ដែល-និយាយពីសកម្មភាពរបស់តំណាង រាស្ត្រ
មែនហើយ យើងត្រូវតែតាមដានទាំងអស់គ្នា ព្រោះយើងជាម្ចាស់ឆ្នោត
មែនហើយ...!!!



សុភា-អាយុ១៨ឆ្នាំ

ដោយសារតែភាពវៃឆ្លាត និងក្លាហាន នាងក្លាយជាទីពឹងពាក់របស់មិត្តភក្រ័។ គ្រួសារនាងមានជីវភាពធូរធារព្រោះជាអ្នកលក់ ដូរ ដូចនេះនាងអាចយកចិត្តទុកដាក់លើការសិក្សា និងជួយដោះ ស្រាយប-ញ្ហារបស់មិត្តភក្រ័។



បូរិន-អាយុ ១៩ឆ្នាំ

បូរិនមានការទទួលខុសត្រូវ ក្លាហាន និងមានឆន្ទះ ។
ដោយសារតែ កំព្រាឪពុក
បូរិនមានតួនាទីរកប្រាក់ជួយផ្គត់ផ្គង់គ្រួសារ។ ក្រៅពីនេះ គេជាអ្នក-សម្របសម្រួលក្លឹបអ្នកស្តាប់កម្មវិធីវិទ្យុ ។



សាឯម-អាយុ១៨ ឆ្នាំ

នាងជាមនុស្សព្រួយចិត្តច្រើន ហើយត្រូវការមិត្តភក្រ័លើកទឹកចិត្ត ។ នាងឆាប់ភ័យ ហើយក៏ឆាប់អរដែរ។ ជីវភាពគ្រួសារនាង មានការលំបាក ជាបន្ទុកមួយសំរាប់នាង។

សរសេរ និងបោះពុម្ពដោយ

EQUAL ACCESS

ផ្ទះលេខ ៣២, ផ្លូវ ៣៩២, សង្កាត់ បឹងកេងកង១, ខ័ណ្ឌ ចំ-
ការមន, ប្រអប់សំបុត្រ ១២១, ក្រុងភ្នំពេញ
ទូរស័ព្ទ : (៨៥៥)២៣ ៩៨៦ ៨២៨ / ៩៨៧ ៤៩៤
ទូរសារ : (៨៥៥)២៣ ៩៨៦ ៨២៩
អ៊ីម៉ែល : wecandoit@equalaccess.org
គេហទំព័រ: www.equalaccess.org

ឧបត្ថម្ភដោយ

TAIWAN FOUNDATION for DEMOCRACY
財團法人臺灣民主基金會

© អង្គការអ៊ីខ្វល អាកសេសកម្ពុជា

រាល់ការចម្លងទាំងអស់ឬការចម្លងផ្នែកណាមួយនៃសៀវភៅនេះ ទោះ-
បីជាតាមរបៀបណាក៏ដោយ ដោយគ្មានការយល់ព្រមពី អង្គការ
អ៊ីខ្វល អាកសេសកម្ពុជា គឺខុសច្បាប់ និងត្រូវមានទោស។
រក្សាសិទ្ធិចំលង និង បកប្រែចំពោះគ្រប់ភាសាទាំងអស់។

ព័ត៌មាន និងទស្សនៈដែលបានបង្ហាញក្នុងសៀវភៅនេះមិនឆ្លុះបញ្ចាំង
ពីទស្សនៈរបស់ Taiwan Foundation for Democracy ទេ។

រូបភាព និងរចនាទំព័រ

ម៉ើ ឌីយ៉ាដារ៉ារុធ និង សៅ ចាន់ណា នៃអង្គការសៀវភៅយើង។

បោះពុម្ពនៅប្រទេសកម្ពុជា

ដោយរោងពុម្ព

## រឿង ចាំសន្យា?



សុភា សាឯម បូរិនជា មិត្តល្អនិងគ្នា។ ពួកគេទាំង៣ ព្រមទាំងមិត្តដ៏ទៃទៀត ដែលរស់នៅក្នុងភូមិជាមួយគ្នា បានបង្កើតជាក្លឹបមួយដើម្បីស្តាប់កម្មវិធី វិទ្យុ។

ដោយសារតែភាពរាំងស្ងួត សាឯម និង បូរិន ត្រូវបានឳពុកម្តាយ ឱ្យឈប់រៀនដើម្បីរកប្រាក់មកជួយដោះស្រាយជីវភាពគ្រួសារ ធ្វើឱ្យគេទាំងពីរពិបាកចិត្តជាខ្លាំង ។

សុភាជាមិត្តល្អម្នាក់ បានលើកទឹកចិត្តមិត្តរបស់នាង ឱ្យព្យាយាមរកដំណោះស្រាយក្នុងរឿងនេះ។

អ្នកភូមិទាំងអស់សុទ្ធតែរង់ចាំ តំណាងរាស្ត្រ (ដែលសន្យាថានឹងជីកប្រឡាយឱ្យក្រោយជាប់ឆ្នោត)។ ជីកាន់តែបែកក្រហែង សន្ទូងក៏ចាប់ផ្តើម ងាប់ ការសន្យាក៏មិនឃើញឆ្លើយតប... តើអ្នកភូមិទាំងអស់ត្រូវរង់ចាំទៀត ឬយ៉ាងណា?